# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 1537

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

## ផ្នែក ក

១. ឈ្មោះគម្រោង : គម្រោងលើកកម្ពស់កម្មវិធីសិក្សារបស់មហាវិទ្យាល័យសិល្បៈសូនរូប សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | 01/01/26 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 31/12/28 |

៣. ចំណាយគម្រោងសរុប $13,036,900

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

| | |
|---|---|
| RESPONSIBLE UNIT | Royal University of Fine Arts |
| អង្គភាពទទួលខុសត្រូវ | សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ |

៥. ស្ថានភាពគម្រោង គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងវិនិយោគជាទុន

៧. ប្រភពហិរញ្ញប្បទាន៖ ស្វែងរកម្ចាស់ជំនួយ

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

បញ្ចកោណទី១- ការអភិវឌ្ឍមូលធនមនុស្ស

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

ចូលរួមពង្រឹងការបណ្តុះបណ្តាលជំនាញចម្លាក់ គំនូរវិចិត្រកម្ម គំនូរឌីជីថល គំនូរសារគមនាគមន៍ ស្មិត ផ្ចិតពុម្ព តុបតែងលម្អ ស្ថាបត្យកម្ម ថ្មែម៉ូតសម្លៀកបំពាក់ ថតរូប និងជួសជុលនិងអភិរក្សចម្លាក់ គំនូរ និងឯកសារឱ្យក្លាយជា មូលធនបញ្ញាជាតិ និងជាឃ្លាំងពុទ្ធិសាកល។

## ១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? គាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

វប្បធម៌ និងសិល្បៈ

១២. ទីតាំងអនុវត្តគម្រោង (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

រាជធានីភ្នំពេញ,

១៣. គោលបំណងរបស់គម្រោង ( ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង )

-បង្កើនឱកាសជូនដល់សាស្ត្រាចារ្យ និងនិស្សិតក្នុងការងារប្រតិបត្តិទាំងទ្រឹស្តី និងការអនុវត្តផ្ទាល់លើជំនាញចម្លាក់ គំនូរវិចិត្រកម្ម គំនូរឌីជីថល គំនូរសារគមនាគមន៍ ស្មិត ផ្តិតពុម្ព តុបតែងលម្អស្ថាបត្យកម្ម ច្នៃម៉ូតសម្លៀកបំពាក់ ថតរូប និងជួសជុលនិងអភិរក្សចម្លាក់ គំនូរ និងឯកសារ

-បង្កើនទីផ្សារការងារលើជំនាញសិល្បៈសូនរូបនៃចម្លាក់ គំនូរវិចិត្រកម្ម គំនូរឌីជីថល គំនូរសារគមនាគមន៍ ស្មិត ផ្តិតពុម្ព តុបតែងលម្អស្ថាបត្យកម្ម ច្នៃម៉ូតសម្លៀកបំពាក់ និងជួសជុលនិងអភិរក្សចម្លាក់និងគំនូរ។

-លើកកម្ពស់ជីវៈភាពសាស្ត្រាចារ្យ និស្សិត និងសហគមន៍មូលដ្ឋានដែលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ

-ពង្រឹង និងពង្រីកទុនវិនិយោគសម្រាប់អភិវឌ្ឍសាកលវិទ្យាល័យ

-ជាមជ្ឈមណ្ឌលប្រមូលផ្តុំធនធានមនុស្សលើគ្រប់ជំនាញផ្នែកសិល្បៈសូនរូបទូទាំងប្រទេស

១៤. ការពិពណ៌នាអំពីគម្រោង ( ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង )

គម្រោងលើកកម្ពស់កម្មវិធីសិក្សារបស់មហាវិទ្យាល័យសិល្បៈសូនរូបនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈនឹងចូលរួមចំណែកក្នុងការពង្រឹងកម្មវិធីសិក្សានូវជំនាញឯកទេសដែលកំពុងអនុវត្តន៍នៅមហាវិទ្យាល័យសិល្បៈសូនរូប បង្កើតកម្មវិធីសិក្សាជំនាញថ្មីៗមួយចំនួនទៀតរួមមានកម្មវិធីគំនូរឌីជីថល សិល្បៈផ្តិតពុម្ព ច្នៃម៉ូតសម្លៀកបំពាក់ ស្មិត ជួសជុលនិងអភិរក្សចម្លាក់ គំនូរ និងឯកសារ។ លើសពីនេះ គម្រោងនេះបានសាងសង់អាគារសិក្សាមួយដែលមានកំពស់ចំនួន ៦ ជាន់ ដែលគាំទ្រលើជំនាញជំនាញទាំងអស់របស់មហាវិទ្យាល័យ។ បន្ថែមពីនេះទៀត គម្រោងនឹងចងក្រងបណ្តាញ និងបង្កើតជាមជ្ឈមណ្ឌលសម្រាប់ការចែករំលែកបទពិសោធន៍ និងបង្កើតថ្មីនៃជំនាញសិល្បៈសូនរូប។ ខាងក្រោមបង្ហាញអំពីគោលដៅ លទ្ធផលរំពឹងទុក និងសមិទ្ធផលនៃគម្រោងក្នុងរយៈពេល ៣ ឆ្នាំ។

1. គោលដៅ Objective

- គាំទ្រកម្មវិធីសិក្សាស្តង់ដាររបស់មហាវិទ្យាល័យសិល្បៈសូនរូបដែលឆ្លើយទៅនឹងឧស្សាហកម្មវប្បធម៌និងឧស្សាហកម្មច្នៃប្រឌិត

2. លទ្ធផល (Outcome)

- កែលម្អកម្មវិធីសិក្សាបច្ចុប្បន្នៈ ចម្លាក់ គំនូរវិចិត្រកម្ម គំនូរសាគមនាគមន៍ តុបតែងលម្អស្ថាបត្យកម្ម) និងបង្កើតកម្មវិធីសិក្សាជំនាញថ្មីៈ គំនូរឌីជីថល ចម្លាក់ស្មិត ផ្តិតពុម្ព ច្នៃម៉ូតសម្លៀកបំពាក់ ថតរូប និងជួសជុលនិងអភិរក្សចម្លាក់ គំនូរ និងឯកសារ

- ពង្រឹងគុណភាពអប់រំជំនាញវិជ្ជាជីវៈសិល្បៈសូនរូបៈ ចម្លាក់ (ចម្លាក់ពុម្ព ចម្លាក់ស្មិត ចម្លាក់ឈើ និងថ្ម) គំនូរវិចិត្រកម្ម គំនូរឌីជីថល គំនូរសារគមនាគមន៍ ផ្តិតពុម្ព តុបតែងលម្អស្ថាបត្យកម្ម ច្នៃម៉ូតសម្លៀកបំពាក់ ថតរូប និងជួសជុល អភិរក្សចម្លាក់ គំនូរនិងឯកសារ

- បង្កើតបណ្តាញទំនាក់ទំនងជំនាញបច្ចេកទេសសិល្បៈសូនរូបតាមតំបន់ និងសហគមន៍

- អាគារកំពស់ ៦ ជាន់ (ទំហំ ៧៥ ម៉ែត្រ x ៣០ ម៉ែត្រ) បម្រើឱ្យរោងជាងសិក្សារបស់ចម្លាក់

a) ជាន់ក្រោមដី (basement) ប្រើប្រាស់ជាចំណតរថយន្ត (៨០គ្រឿង) និងទោចក្រយាន្ត(១០០ គ្រឿង)

b) ជាន់ផ្ទាល់ដីប្រើប្រាស់សម្រាប់ការងារបណ្តុះបណ្តាលលើជំនាញសិល្បៈផ្តិតពុម្ព ចម្លាក់( ចម្លាក់ពុម្ព ចម្លាក់ស្មិត ចម្លាក់ឈើ និងថ្ម) ជួសជុលនិងអភិរក្សចម្លាក់

c) ជាន់ទី ១ ប្រើប្រាស់សម្រាប់រោងជាងវិចិត្រកម្ម និងថតរូប

d) ជាន់ទី ២ ប្រើប្រាស់សម្រាប់រោងជាងឯកទេសសារគមនាគមន៍ និងការរចនាម៉ូតសម្លៀកបំពាក់

e) ជាន់ទី ៣ ប្រើប្រាស់សម្រាប់រោងជាងឯកទេសតុបតែងលម្អនៃស្ថាបត្យកម្ម

f) ជាន់ទី ៤ ប្រើប្រាស់សម្រាប់រោងជាងជួសជុល និងអភិរក្សឯកសារ និងរោងជាងពិសោធន៍ថ្នាំពណ៌

g) ជាន់ទី ៥ ប្រើប្រាស់សម្រាប់ថ្នាក់ទ្រឹស្តី និងសាលសហសិក្សា

h) ដំបូល

3. សមិទ្ធផល (Output)

- ផលិតធនធានមនុស្សលើវិស័យសិល្បៈសូនរូបប្រកបដោយគុណភាព សមត្ថភាព និងសីលធម៌

- គាំទ្រគោលនយោបាយជាតិស្តីពីវិស័យវប្បធម៌

- កម្មវិធីសិក្សាបច្ចុប្បន្ន និងកម្មវិធីសិក្សាជំនាញថ្មីដែលមានស្តង់ដារត្រូវបានដាក់ឱ្យប្រើប្រាស់

- បង្កើនទីផ្សារការងារលើជំនាញសិល្បៈចម្លាក់ គំនូរវិចិត្រកម្ម គំនូរសាគមនាគមន៍ តុបតែងលម្អស្ថាបត្យកម្ម) និងបង្កើតកម្មវិធីសិក្សាជំនាញថ្មីៈ គំនូរឌីជីថល ចម្លាក់ស្មិត ផ្តិតពុម្ព ច្នៃម៉ូតសម្លៀកបំពាក់ ថតរូប និងជួសជុលនិងអភិរក្សចម្លាក់ គំនូរ និងឯកសារ

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

ជំនាញសិល្បៈសូនរូបគឺជាជំនាញតែមួយគត់នៅប្រទេសកម្ពុជាដែលមានបណ្តុះបណ្តាលនៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។ គម្រោងនេះត្រូវបានរៀបចំកសាងឡើងដើម្បីឆ្លើយតទៅនឹងតម្រូវការចាំបាច់ក្នុងការបណ្តុះបណ្តាលប្រកបដោយប្រសិទ្ធភាព និងគុណភាពដោយភ្ជាប់នូវកន្លែងបណ្តុះបណ្តាលធំទូលាយ និងផ្គត់ផ្គង់សម្ភារបណ្តុះបណ្តាលគ្រប់គ្រាន់គាំទ្រដល់ការច្នៃប្រឌិតបង្កើតថ្មីមួយចំនួននៃជំនាញដែលបានរៀបរាប់ខាងលើ។ ម្យ៉ាងវិញទៀត សហគមន៍ជំនាញសិល្បៈសូនរូបនៅរាយប៉ាយទូទាំងប្រទេសដែលយើងត្រូវចងក្រង និងផ្តល់ឱកាស និងកន្លែងជូនដល់សហគមន៍ភ្ជាប់ទំនាក់ទំនង និងចែករំលែកបទពិសោធន៍ និងចងក្រងបណ្តាញទាំងការងារ និងទីផ្សារសិល្បៈ។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

**អ្នកទទួលផលដោយផ្ទាល់៖**

- សាកលវិទ្យាល័យ និងមហាវិទ្យាល័យសិល្បៈសូនរូបដែលមានឯកទេសដូចបានរៀបរាប់ខាងលើ រួមមាន៖ បុគ្គលិកសិក្សា សាស្ត្រាចារ្យ និស្សិតដែលសិក្សាឯកទេសសិល្បៈសូនរូប សហគមន៍ដែលបានកំណត់អត្តសញ្ញាណ សិល្បៈករលើវិស័យសិល្បៈសូនរូប

**អ្នកទទួលផលដោយប្រយោល៖**

- ប្រជាជនកម្ពុជា, អ្នកទេសចរ, ប្រជាសហគមន៍តាមតំបន់សហគមន៍សិល្បៈសូនរូប

**១៧. ការសិក្សាសមិទ្ធិលទ្ធភាព**

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? **មាន**

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? **ត្រូវបានរៀបចំ**

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

**មិនមានផលប៉ះពាល់ដល់បរិស្ថាន**

**គម្រោងបានចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រព្រោះ៖**

**១.បង្កើតការងារក្នុងវិស័យសិល្បៈតាមរយៈការបណ្តុះបណ្តាលធនធានមនុស្សដែលឆ្លើយតបទៅនឹងទីផ្សារការងារទាំងសាស្ត្រាចារ្យ និងនិស្សិត ក៏ដូចជាសហគមន៍ជំនាញសិល្បៈសូនរូប**

**២.បង្កើតម្លៃសេដ្ឋកិច្ច និងបង្កើតមូលដ្ឋានគ្រឹះនៃឧស្សាហកម្មវប្បធម៌**

**និងបង្កើនការយល់ដឹងអំពីសិល្បៈវប្បធម៌របស់ខ្លួនតាមរយៈផលិតសម្ភារអនុស្សាវរីយដើម្បីលក់ជូនភ្ញៀវជាតិ និងភ្ញៀវអន្តរជាតិ។**

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **គ្មាន**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
|---|---|---|

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **គ្មាន**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**គម្រោងនេះនិងផ្តល់ឱកាសជូនដល់ស្ត្រីយ៉ាងតិចចំនួន ៤0% នៃចំនួនមន្ត្រីគម្រោងសរុបក្នុងមុខតំណែងធ្វើសេចក្តីសម្រេចចិត្ត។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**ដោយមានបទពិសោធន៍ពីគម្រោងវិទ្យាស្ថានអប់រំ ស្រាវជ្រាវសិល្បៈនិងវប្បធម៌ដែលកំពុងអនុវត្ត នោះមន្ត្រីគម្រោងអាចធ្វើការគ្រប់គ្រង ត្រួតពិនិត្យ និងវាយតម្លៃគម្រោងទៅតាមផែនការសកម្មភាព និងអាចធ្វើការកែតម្រូវគម្រោងអាស្រ័យទៅបញ្ហាប្រឈម និងករណីប្រធានសក្តិ។**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

**មិនមានទាន់មានសកម្មអនុវត្តនៅឡើយ**

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

1

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

**មិនទាន់មាន**

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 468.1 | 384.4 | 384.4 | 1,236.9 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 296.0 | 296.0 | 296.0 | 888.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 17.7 | 14.0 | 14.0 | 45.7 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 154.4 | 74.4 | 74.4 | 303.2 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 2,428.0 | 7,496.0 | 1,876.0 | 11,800.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 2,211.0 | 7,189.0 | 1,658.0 | 11,058.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 177.0 | 187.0 | 178.0 | 542.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 40.0 | 120.0 | 40.0 | 200.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 0.0 | 0.0 | 0.0 | 2,896.1 | 7,880.4 | 2,260.4 | 13,036.9 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | |
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ថវិកាជាតិ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 0.0 | 0.0 | 0.0 | 2,896.1 | 7,880.4 | 2,260.4 | 13,036.9 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: